# ភាជនីយភណ្ឌ[1]

នៅក្នុង សង្គម សុខដុម សមាជិក ម្នាក់ៗ ទទួល បាន ចំណែក ត្រឹមត្រូវ ពី ភាពសម្បូណ៌ ឬ សារពើ សេដ្ឋកិច្ច មាន ផល ល្អ របស់ សង្គម។ ចំណែក នេះ ជា មូលដ្ឋាន នៃ សមភាព និង យុត្តិធម៌ រវាង សមជិក ទាំងឡាយ។ ពិតណាស់ហើយ នៅក្នុង សង្គម សេរី វា តែងតែ មាន អ្នកមាន អ្នកក្រ តែ ចំណែក សម្បរម នោះ វា អនុញ្ញាត អោយ អ្នកក្រ រស់នៅ ដោយ សេចក្ដីថ្លៃថ្នូរ ជា មនុស្ស ចំណែក អ្នកមាន គេ មិន ចាត់ទុក ថា ជា មនុស្ស លោភលន់។ ទាំង អ្នកក្រ និង អ្នកមាន មាន អារម្មណ៍ ដោយ ជំនឿ ដូចគ្នា ថា ខ្លួន បាន ចូលរួមចំណែក នៅក្នុង ផលិត ផ្លែផ្កា ល្អ នៃ ការ ពង្រិក ផល នៃ សង្គម។ អារម្មណ៍ នេះ ជា មូលដ្ឋាន នៃ យុត្តិធម៌ រួមគ្នា ព្រោះ គុណស្រ័យ ដែល បាន កសាង រៀងៗ ខ្លួន ត្រូវ បាន អ្នកផង ទទួលស្គាល់ ទៅវិញទៅមក។

ចំណែក ត្រឹមត្រូវ នេះឯង ជា មូលប្រណិធាន[2] នៃ មូលធននិយម របស់ ពួក អ្នកសង្គម-ប្រជាធិបតី។ វា ជា គំនិតគ្រឹះ ខុសស្រឡះ ពី គំនិត « អរគុណ សន្តិភាព » របស់ របប ផ្ដាច់ការ ទុកខ្លួន ជា ជិនបក្ស[3] ដែល តែងតែ និយាយ ក្នុងនាម នៃ ប្រជាពលរដ្ឋ តែ ពលរដ្ឋ ម្នាក់ៗ គ្មានបាន ទទួល ចំណែក ត្រឹមត្រូវ ដើម្បី រស់នៅ មាន សេចក្ដីថ្លៃថ្នូរ ជា មនុស្ស៕

---

1 ភាជនីយភណ្ឌ : (ភាជៈនីយៈភ័ន) ន. របស់ដែលគួរចែកគ្នាបាន។
2 មូលប្រណិធាន : សេចក្ដីប្រាថ្នាដើម។
3 ជិនបក្ស : បក្ស នៃ អ្នកឈ្នះ។